# លក្ខខន្តិកៈ

## ការធានារ៉ាប់រងលើអាយុជីវិតស្មាត

### <u>នរណានឹងទទួលបានការធានា?</u>

ការធានារ៉ាប់រងអាយុជីវិតស្មាត - ម្ចាស់ប័ណ្ណសន្យារ៉ាប់រង នឹងសាច់ញាតិធានារ៉ាប់រងជីវិតទាំងអស់ត្រូវតែមានឈ្មោះនៅក្នុងគោលការណ៍ដើម្បីទទួលការធានារ៉ាប់រង ហើយអ្នកត្រូវតែជាអតិថិជនដែរប្រើប្រាស់ស៊ីមស្មាតដែលបានធ្វើការចុះឈ្មោះ។

### <u>អាយុ:</u>

អ្នកត្រូវតែមានអាយុចន្លោះពី 18-69ឆ្នាំ(ទាំងពីរត្រូវបានរាប់បញ្ចូល)។ សម្រាប់អ្នកទទួលផលសំណងគឺទទួលបានការធានារ៉ាប់រងដោយឥតគិតថ្លៃ ហើយ នាង/គាត់ត្រូវតែជាអតិថិជនដែរប្រើប្រាស់ស៊ីមស្មាតជាប្រភេទស៊ីមបញ្ចូលលុយមុនប្រើប្រាស់ក្រោយ និងមានអាយុចន្លោះពី 18-69ឆ្នាំ(ទាំងពីរត្រូវបានរាប់បញ្ចូល)។ សម្រាប់អ្នកទទួលផលសំណង គឺចាប់ផ្តើមទទួលបាននៅថ្ងៃដូចគ្នា ហើយអត្ថប្រយោជន៍ក៏ទទួលបានដូចគ្នានឹងម្ចាស់ប័ណ្ណសន្យាដែរ។

### <u>ការកាត់ទឹកប្រាក់ នឹងការធានា:</u>

- ការកាត់ទឹកប្រាក់បុព្វលាភ នឹងទទួលបានការធានារ៉ាប់រង 100% ដោយឥតគិតថ្លៃ(ទាំងម្ចាស់ប័ណ្ណសន្យា នឹងអ្នកទទួលផលសំណង ហើយចាប់ផ្តើមទទួលបាននៅក្នុងថ្ងៃដំបូងបន្ទាប់ពីការចុះឈ្មោះ ហើយការធានារ៉ាប់រងនេះដែរគឺទទួលបានបន្ទាប់ពីមានការកាត់ទឹកប្រាក់បានជោគជ័យ។ ឧទាហរណ៍៖ ប្រសិនបើលក្ខិណាធ្វើការចុះឈ្មោះនៅថ្ងៃទី15 ខែមករា ហើយទឹកប្រាក់បុព្វលាភរបស់នាងគឺត្រូវបានកាត់ នឹងទទួលបានការធានារ៉ាប់រង 100%លើគ្រោះថ្នាក់ចៃដន្យនៅក្នុងថ្ងៃទី16 ខែមករា ហើយនាងក៏ទទួលបានការធានារ៉ាប់រងនៅក្នុងថ្ងៃទី1 ខែមិនា គឺអាស្រ័យលើចំនួនទឹកប្រាក់ដែរបានកាត់នៅខែមុន (ទាំងគ្រោះថ្នាក់ចៃដន្យ នឹងជំងឺ)។
- ប្រសិនបើចំនួនទឹកប្រាក់បុព្វលាភរ៉ាប់រងពេញលេញមិនត្រូវបានកាត់ក្នុងរយៈពេលមួយខែ នោះផ្នែកខ្លះនឹងត្រូវផ្តល់ជូនដោយផ្អែកលើចំនួនទឹកប្រាក់ជាក់ស្តែងដែលបានកាត់។
- ការទាមទារសំណងត្រូវបានទុករយៈពេលរហូតដល់ 3 ខែនៃការទទួលមរណៈភាពរបស់ម្ចាស់ប័ណ្ណ។ ដើម្បីមានសិទ្ធិទាមទារសំណង, ម្ចាស់ប័ណ្ណមិនត្រូវមានបញ្ហាសុខភាពមុនពេលចុះឈ្មោះ។

### <u>របៀបក្នុងការទាមទារសំណង:</u>

- ដំណើរការនៃការទាមទារសំណងនឹងចាប់ផ្តើមបន្ទាប់ពីឯកសារខាងក្រោមត្រូវបានដាក់ជូន៖

A. ភស្តុតាងនៃការចុះឈ្មោះ (សារបញ្ជាក់ពីការចុះឈ្មោះ ឬការធានារ៉ាប់រង) ។
B. ឯកសារបញ្ជាក់ពីអត្តសញ្ញាណ (អត្តសញ្ញាណប័ណ្ណ, សៀវភៅគ្រួសារ, ប័ណ្ណបើកបរ ឬលិខិតឆ្លងដែន) ។
C. ភ័ស្តុតាងនៃការមរណៈភាព (លិខិតបញ្ជាក់មរណៈភាព, លិខិតវេជ្ជសាស្ត្របញ្ជាក់ពីមូលហេតុនៃការស្លាប់ ឬលិខិតផ្លូវការបញ្ជាក់ពីភូមិ ឬសង្កាត់) ។

**<u>ករណីលើកលែងមិនផ្តល់សំណង:</u>**

- សំណងដែរមិនទទួលបានការការពារប្រសិនបើការស្លាប់កើតឡើងដោយផ្ទាល់ ឬដោយប្រយោលពីបញ្ហាណាមួយដូចខាងក្រោម៖
  A. ការធ្វើអត្តឃាត
  B. សង្គ្រាម, ការបះបោរ, កុបកម្ម ឬចលាចលស៊ីវិល
  C. ការប្រព្រឹត្ត ឬញុះញង់បទល្មើសព្រហ្មទណ្ឌ,ការទទួលទានគ្រឿងញៀនខុសច្បាប់ គ្រឿងញៀន ឬអាល់កុលក្រៅពីវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិត
  D. ការមិនបង្ហាញអំពីស្ថានភាពសុខភាពដែលមានមុនពេលចុះឈ្មោះ

**<u>ការកាត់ផ្តាច់សេវាកម្ម:</u>**

តាមគោលការណ៍នេះអាចធ្វើការលុបចោលសេវាកម្មធានារ៉ាប់រងដោយទូរស័ព្ទទៅប៊ីម៉ាតាមរយៈលេខ 010 242 248។ ការកាត់បុព្វលាភនឹងត្រូវបញ្ឈប់ក្នុងរយៈពេល 48 ម៉ោង។